ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាអនុវត្តការងារ

លេខ៖ ១០/១៣ FWUC_SCN-ISC

## គាំទ្រលើកិច្ចដំណើរការសហគមន៍កសិករប្រើប្រាស់ទឹក ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្រុកសន្ទុក ខេត្តកំពង់ធំ

កំឡុងពេល ខែមករា ដល់ ខែមេសា ឆ្នាំ២០១១

រវាង

**គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក**

និង

**មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ**
**ខេត្តកំពង់ធំ**

ខែធ្នូ ឆ្នាំ ២០១០

# កិច្ចសន្យាអនុវត្តការងារ

*កំឡុងពេល ខែមករា ដល់ ខែមេសា ឆ្នាំ២០១១*

*គាំទ្រលើកិច្ចដំណើរការសហគមន៍កសិករប្រើប្រាស់ទឹក*

*ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្រុកសន្ទុក ខេត្តកំពង់ធំ*

លេខៈ ១០/១៣ FWUC_SCN-ISC

*កិច្ចសន្យានេះរៀបចំឡើងរវាង សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ជាភាគីម្ចាស់គម្រោង ដែលតំណាងដោយ* ***លោក គៀម ប៊ុនរ៉ុង*** *ជាប្រធានគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នឹង មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ជាភាគីអនុវត្តគម្រោង ដែលតំណាងដោយ* ***លោក សេង សុភ័គ*** *ជាអ្នកសម្របសម្រួលមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។*

**ប្រការ ១ គោលបំណង**

មជ្ឈមណ្ឌលសេវាម្មធារាសាស្ត្រ នឹងផ្តល់សេវាកម្មជូនសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិតកំឡុងពេលពី ខែ មករា ដល់ ខែ មេសា ឆ្នាំ២០១១ ៖

១. ការគ្រប់គ្រងហិរញ្ញវត្ថុ

- ត្រួតពិនិត្យរបាយការណ៍ចំណាយប្រចាំខែ ចំនួន ១២ច្បាប់
- ធ្វើរបាយការណ៍បូកសរុបចំណូលចំណាយប្រចាំឆ្នាំ ២០១០-២០១១

២. ការងារសម្របសម្រួល និងគាំទ្រដល់គណៈកម្មាធិការសហគមន៍

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់សហគមន៍កសិករប្រើប្រាស់ទឹក ២០១១-២០១២
- បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ២០១០-២០១១ ជូនមន្ទីរធនធានទឹក ក្រសួងធនធានទឹក
- បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ២០១០-២០១១ ជូនម្ចាស់ជំនួយពាក់ព័ន្ធ
- រៀបចំសំណើរស្វែងរកមូលនិធិសំរាប់គាំទ្រដល់កិច្ចដំណើរការរបស់សហគមន៍
- រៀបចំសំណើរស្វែងរកមូលនិធិសំរាប់គាំទ្រលើការកែលំអរ និងជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ ដាក់ជូនឃុំ ស្រុក និងក្រសួងធនធានទឹក
- ចូលរួម និងសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការទ្រទ្រង់អាងទឹកស្ទឹងជីនិត
- កិច្ចសហការជាមួយអាជ្ញាធរដែនដី (ឃុំ ស្រុក ខេត្ត) និងម្ចាស់ជំនួយនានាក្នុងការពង្រីកតំបន់ស្រោចស្រព
- ត្រួតពិនិត្យរបាយណ៍សកម្មភាពប្រចាំឆ្នាំរបស់សហគមន៍កសិករប្រើប្រាស់ទឹក ២០១០-២០១១

**ប្រការ ២ លំអិតលើសកម្មភាពការងារ និងរយៈពេលសំរាប់អនុវត្ត**

សកម្មភាពការងារត្រូវអនុវត្តក្នុងកំឡុងពេល ខែ មករា ឆ្នាំ២០១១ ដល់ខែមេសា ឆ្នាំ២០១១ មានដូចខាងក្រោម៖

| ល.រ | បរិយាយអំពីការងារត្រូវអនុវត្ត | ចំនួនថ្ងៃធ្វើការ | ពេលវេលាអនុវត្ត |
|---|---|---|---|
| ១ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ០៧ ថ្ងៃ | ខែមករា ឆ្នាំ ២០១១ |
| ២ | ការងារសម្របសម្រួល និងគាំទ្រដល់គណៈកម្មាធិការ | តាមជាក់ស្តែង | ឆ្នាំ ២០១១ |
| | សរុប | | |

ការអនុវត្តន៍ការងារដែលមាននៅក្នុងកិច្ចសន្យានេះ នឹងចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី ៣០ខែមេសា ឆ្នាំ២០១១។

**ប្រការ ៣ គម្រោងចំណាយលើការអនុវត្តន៍សកម្មភាពការងារក្នុងកិច្ចសន្យា**

ការចំណាយលើការអនុវត្តន៍សកម្មភាពការងារទាំង ២ ខាងលើនេះ អស់ប្រាក់សរុបចំនួន ៣៥០ដុល្លា។

| ចំនួនថ្ងៃធ្វើការសរុប | តំលៃការងារក្នុង ១ ថ្ងៃ | ចំណាយសរុប |
|---|---|---|
| ៧~១៧ ថ្ងៃ | ២០ដុល្លា | ១៤០-៣៥០ដុល្លា |

រាល់ការចំណាយផ្សេងៗ លើការអនុវត្តន៍សកម្មភាពការងារទាំង ២ ខាងលើនេះ សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ជាអ្នកទទួលខុសត្រូវ។

**ប្រការ ៤ ការបង់ប្រាក់ថ្លៃអនុវត្តសកម្មភាពការងារ**

ការបង់ប្រាក់ នឹងត្រូវធ្វើឡើងដោយសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្ទេរប្រាក់ចូលទៅក្នុងគណនីរបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រផ្ទាល់ បន្ទាប់ពីការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារ ដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១១។

**ប្រការ ៥ ឯកសារផ្សេងៗ និងរបាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារ**

ក្រោយពេលបញ្ចប់កិច្ចសន្យា រយៈពេលមួយសប្តាហ៍ មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ នឹងផ្តល់របាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារតាមកិច្ចសន្យា ជូនគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត។

**ប្រការ ៦ ការវាយតំលៃលើការអនុវត្តន៍គម្រោង**

ការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១១។ ការវាយតំលៃនេះផ្តោតសំខាន់ទៅលើពីរចំណុច៖

១. ការសំរេចនូវគោលបំណង ដូចមានចែងក្នុងប្រការ១ និង ២. ធ្វើការឆ្លុះបញ្ចាំងលើនិតិវិធីនៃកិច្ចសហការក្នុងការអនុវត្តន៍ការងារកន្លងមក ដើម្បីស្វែងរកចំណុចល្អ និងចំណុចត្រូវកែលំអសំរាប់អនុវត្តទៅថ្ងៃអនាគត។

**ប្រការ ៧ ការដោះស្រាយទំនាស់**

ករណីមានទំនាស់កើតឡើងពាក់ព័ន្ធនិងកិច្ចសន្យានេះ ភាគីទាំងពីរ នឹងជួបពិភាក្សាគ្នាដើម្បីរកដំណោះស្រាយសមស្របមួយដែលអាចទទួលបានការឯកភាពពីភាគីទាំងពីរ។ ករណីមិនអាចពិភាក្សារវាងភាគីទាំងពីរទំនាស់នេះ នឹងបញ្ជូនទៅដោះស្រាយនៅតុលាកម្ពុជា។

**ប្រការ ៨ សុពលភាពនៃកិច្ចសន្យា**

កិច្ចសន្យានេះ នឹងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រវាងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

**ប្រការ ៩ ការធ្វើវិសោធនកម្មនៃកិច្ចសន្យា**

កិច្ចសន្យានេះ អាចនឹងត្រូវធ្វើការកែប្រែ ករណីមានការឯកភាពទាំងពីរភាគី រវាងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ស្ទឹងជីនិត និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

ធ្វើនៅ ឃុំកំពង់ថ្ម ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

| | |
|---|---|
| *មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ* | *គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក* |
| *អ្នកសម្របសម្រួល* | *ប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត* |
| | ប្រធាន |
| **លោក សេខ សុភ័គ** | **លោក កៀម ម៉ិនរ៉ុខ** |

*កិច្ចសន្យាការងាររវាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រនិងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត -*